០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**នៅចំពោះមុខ អង្គជំនុំជម្រះសាលាដំបូង**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 13-Sep-2011, 08:15
CMS/CFO: Uch Arun

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អជជ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស (បកប្រែជាភាសា ខ្មែរ)

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ: **សាធារណៈ/Public**

ឋានៈនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះអង្គជំនុំជម្រះសាលាដំបូងសុំឲ្យចាត់ថ្នាក់ឡើងវិញនូវឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលសវនាការបឋមស្តីពីសម្បទាចូលរួមក្នុងសវនាការ ពីឯកសារសម្ងាត់បំផុតទៅជាឯកសារសម្ងាត់ និងជូនដំណឹងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អំពីឯកសារទាំងនោះ**

---

ដាក់ដោយ៖

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

Ms. Elisabeth SIMONNEAU FORT

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី ជេត វណ្ណលី

លោក ហុង គីមសួន

នៅចំពោះមុខ៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម Silvia CARTWRIGHT

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម ធូ មណី

លោក គីម ម៉េងឃី

លោក គង់ ពិសី

លោក ឡោ ជុនធី

លោកស្រី ម៉ុច សុវណ្ណារី

លោក សំ សុគង់

លោកស្រី ស៊ិន សុវ៉ន

លោកស្រី ទី ស្រ៊ីនណា

លោក វ៉េន ពៅ

លោក យ៉ុង ផានិត

Emmanuel ALTIT
Pascal AUBOIN
Olivier BAHOUGNE
Patrick BAUDOIN
Evelyne BOILEAU-BRANDOMIR
Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Marie GUIRAUD
Emmanuel JACOMY
Martine JACQUIN
Daniel LOSQ
Christine MARTINEAU
Mahdev MOHAN
Barnabe NEKUIE
Lyma NGUYEN
Elisabeth RABESANDRATANA
Julien RIVET
Fabienne TRUSSES-NAPROUS
Nushin SARKARATI
Silke STUDZINSKY
Philippine SUTZ

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

យ៉េត ចរិយា

William SMITH

**ជនជាប់ចោទ៖**

ខៀវ សំផន

អៀង សារី

អៀង ធីរិទ្ធ

នួន ជា

**សហមេធាវីការពារក្តី៖**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

លោក អាង ឧត្តម

លោក Michael G. KARNAVAS

លោក ផាត់ ពៅស៊ាង

លោកស្រី Diana ELLIS

លោក ស ស្វូវ៉ាន

លោក Jacques VERGES

សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះអង្គជំនុំជម្រះសាលាដំបូងសុំឱ្យ
ចាត់ថ្នាក់ឡើងវិញនូវឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល
សវនាការបឋមស្តីពីសម្បទាចូលរួមក្នុង សវនាការ ពីឯកសារសម្ងាត់បំផុតទៅជាឯកសារសម្ងាត់
និងជូនដំណឹងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អំពីឯកសារទាំងនោះ

**ប្រវត្តិនីតិវិធី**

១. នៅថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូង បានចេញអនុស្សរណៈមួយ[1] ផ្ញើជូនគ្រប់ភាគីដោយជម្រាបថារបាយការណ៍វេជ្ជសាស្ត្រអ្នកជំនាញទាក់ទងនឹងអៀង ធីរិទ្ធ និង នួន ជា នៅតែត្រូវចាត់ថ្នាក់ជាឯកសារសម្ងាត់បំផុត តាមសំណើរបស់មេធាវីការពារក្ដីរបស់ពួកគាត់ដែលស្នើឲ្យរក្សាចំណាត់ថ្នាក់ឯកសារនៅដដែល[2]។

២. ទោះបីយ៉ាងណា អង្គជំនុំជម្រះសាលាដំបូងផ្ដល់សិទ្ធិឲ្យសហព្រះរាជអាជ្ញា និងក្រុមមេធាវីការពារក្ដីជនជាប់ចោទនីមួយៗ និងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីមើលឯកសារទាំងនេះ។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានអនុញ្ញាតឲ្យផ្ដល់ឯកសារទាំងនេះ “ទៅឲ្យមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីណាមួយបាន តែក្នុងករណីមានការព្រមព្រៀងរវាងសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដោយអនុលោមតាមវិធាន ១២ ស្ទួនពីរ(៥)(ខ) និង(៦) ហើយមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីនោះនឹងធ្វើនូវសេចក្ដីសន្និដ្ឋានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរក្នុងនាមដើមបណ្ដឹងរដ្ឋប្បវេណីរួមក្រុមប៉ុណ្ណោះ។[3]” នៅថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០១១ សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើឲ្យកែតម្រូវអនុស្សរណៈ[4] ដើម្បីឲ្យមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីទទួលបានសិទ្ធិមើលឯកសារទាំងនេះ។ នៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១ ចៅក្រមភាគច្រើននៃអង្គជំនុំជម្រះសាលាដំបូងបានច្រានចោលសំណើនេះ[5]។ នៅថ្ងៃទី ១៨ ខែ សីហា សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្ប

---

[1] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ជូនមេធាវីគ្រប់ភាគីនៃរឿងក្ដីទាក់ទងនឹងចំណាត់ថ្នាក់នៃរបាយការណ៍របស់អ្នកជំនាញ E62/3/10 ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១

[2] សេចក្ដីជំទាស់របស់ក្រុមមេធាវីការពារក្ដីទៅនឹងការប្រកាសរបស់អង្គជំនុំជម្រះសាលាដំបូងអំពីការដាក់របាយការណ៍របស់វេជ្ជបណ្ឌិត CAMPBELL ទៅក្នុងផ្នែក “សម្ងាត់” នៃសំណុំរឿង E62/3/10/7 ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ជូនមេធាវីគ្រប់ភាគីនៃរឿងក្ដីទាក់ទងនឹងចំណាត់ថ្នាក់នៃរបាយការណ៍របស់អ្នកជំនាញ E62/3/10 ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០១១ ទំព័រទី២

[4] សារណាបន្ទាន់ស្នើអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សារណៈ E62/3/10 (អនុស្សារណៈចាស់ E106), E62/3/10/1, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១

[5] សេចក្ដីសម្រេចលើ “សារណាបន្ទាន់របស់សហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីស្នើអង្គជំនុំជម្រះសាលាដំបូងកែតម្រូវអនុស្សារណៈ E62/3/10 (អនុស្សារណៈចាស់ E106)”, E62/3/10/4, ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១

វេណីបានដាក់សារណាមួយ ក្នុងគោលបំណងស្នើសុំឲ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាឡើងវិញ និងកែតម្រូវអនុស្សរណៈខាងលើ[6]។ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ ជំហររបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលការគាំទ្រនៅក្នុងយោបល់ជំទាស់ របស់ចៅក្រម Jean-Marc Lavergne[7]។

៣. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១ សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី បានដាក់សេចក្តីសុំប្តឹងសារទុក្ខជំទាស់នឹងសេចក្តីសម្រេចចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១១[8]។

៤. ក្នុងអំឡុងពេលសវនាការបឋមជាសាធារណៈស្តីពីសម្បទាចូលរួមសវនាការពីថ្ងៃទី ២៩ ដល់ ៣១ ខែសីហា ឆ្នាំ២០១១ ឯកសារមួយចំនួនទាក់ទងនឹងបញ្ហានេះរួមទាំងមតិអ្នកជំនាញរបស់សាស្ត្រាចារ្យ Campbell ត្រូវបានលើកយកពិភាក្សាជាសាធារណៈ។

៥. អង្គជំនុំជម្រះសាលាដំបូង បានរំលឹកឡើងវិញថាការពិភាក្សាអំពីបញ្ហាវេជ្ជសាស្ត្រ និងសម្បទាក្នុងការចូលរួមការជំនុំជម្រះគួរតែប្រព្រឹត្តទៅក្នុងសវនាការសាធារណៈ។ លើសពីនេះទៀត អង្គជំនុំជម្រះសាលាដំបូង បានរំលឹកឡើងវិញថាមិនតម្រូវឲ្យមានលក្ខខណ្ឌផ្លូវការឡើយ នៅពេលដែលភាគីមានបំណងដាក់ឯកសារ ដែលត្រូវបានចាត់ថ្នាក់ជាបឋមជាឯកសារសម្ងាត់ និងសម្ងាត់បំផុត នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងសវនាការសាធារណៈឡើយ។ អង្គជំនុំជម្រះសាលាដំបូង បានលើកឡើងថាក្នុងករណីនេះ “ដរាបណាមិនមានការជំទាស់ពីអង្គជំនុំជម្រះទេ ឯកសារ

---

[6] សារណាស្តីពីការសំណើសុំធ្វើការពិចារណាឡើងវិញ និងកែតម្រូវអនុស្សរណៈ E62/3/10/4, E62/3/10/4/1, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០១១

[7] មតិជំទាស់របស់ចៅក្រម Jean-Marc Lavergne ពាក់ព័ន្ធនិងសេចក្តីសម្រេចដែលចេញដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងអនុស្សារណៈ E62/3/10/4 ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១១

[8] សេចក្តីសុំប្តឹងសារទុក្ខរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីជំទាស់នឹងសេចក្តីសម្រេចលេខ E62/3/10/4 ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១១

សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះអង្គជំនុំជម្រះសាលាដំបូងសុំឲ្យចាត់ថ្នាក់ឡើងវិញនូវឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេលសវនាការបឋមស្តីពីសម្បទាចូលរួមក្នុង សវនាការ ពីឯកសារសម្ងាត់បំផុតទៅជាឯកសារសម្ងាត់ និងជូនដំណឹងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អំពីឯកសារទាំងនោះ

នោះត្រូវចាត់ទុកថាបានចាត់ថ្នាក់ជាឯកសារសារធារណៈ”[9]។

៦. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងក្នុងសារណាជាច្រើនកន្លងមក អំពីសារៈសំខាន់ និងសិទ្ធិពេញលេញរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានការជូនដំណឹងអំពីឯកសារទាំងនេះ ដើម្បីឲ្យពួកគាត់អាចបំពេញអាណត្តិការងារវិជ្ជាជីវៈរបស់ខ្លួនជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងធានាបាននូវការតំណាងកូនក្តីរបស់ពួកគាត់ដោយប្រសិទ្ធិភាព។

៧. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី កត់សម្គាល់ផងដែរថាសារណាដាក់ដោយសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងសំនួរដែលបានដាក់ជូនអ្នកជំនាញដែលត្រូវបានចាត់តាំងថ្មីចំនួន៤រូប និងសារណារបស់មេធាវីការពារក្តី អៀង ធីរិទ្ធ ពាក់ព័ន្ធនឹងសំណួរ និងមតិយោបល់នានាសម្រាប់អ្នកជំនាញថ្មីត្រូវបានចាត់ថ្នាក់ជាឯកសារសម្ងាត់[10]។

៨. ឯកសារទាំងឡាយ ដែលពីដំបូងត្រូវបានចាត់ថ្នាក់ជា “ឯកសារសម្ងាត់បំផុត” កន្លងមកត្រូវបានលើកយកមកពិភាក្សាក្នុងសវនាការសាធារណៈរួចហើយ។ លើសពីនេះ សេចក្តីសង្ខេបរួមនៃខ្លឹមសារ និងសេចក្តីសន្និដ្ឋានរបស់ឯកសារទាំងនោះ ក៏ត្រូវបានបង្ហាញឲ្យដឹងជាសាធារណៈផងដែរ។ ហេតុដូច្នេះ គេគួរយល់ថាចំណាត់ថ្នាក់សម្ងាត់បំផុតនៃឯកសារទាំងនេះត្រូវបានផ្លាស់ប្តូរហើយ ដែលជាគោលការណ៍ថៅក្រមក្នុងអង្គជំនុំជម្រះសាលាដំបូងគួរបានជ្រាបអំពីការផ្លាស់ប្តូរនេះ លើកលែងតែក្នុងករណីមួយចំនួនតូចប៉ុណ្ណោះ។

---

[9] ប្រតិចារឹត E1/10/1, ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១ ទំព័រទី២

[10] សំណួរ និងមតិយោបល់នានារបស់មេធាវីការពារក្តី អៀង ធីរិទ្ធ សម្រាប់អ្នកជំនាញដោយអនុលោមតាម “ដីកាចាត់តាំងអ្នកជំនាញរបស់អង្គជំនុំជម្រះសាលាដំបូង” E111/3 ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១ សំណួរ និងមតិយោបល់របស់សហព្រះរាជអាជ្ញា សម្រាប់អ្នកជំនាញវិកលវិទ្យាពាក់ព័ន្ធនឹងជនជាប់ចោទ E111/2 ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១១
សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីចំពោះអង្គជំនុំជម្រះសាលាដំបូងសុំឲ្យ
ចាត់ថ្នាក់ឡើងវិញនូវឯកសារដែលដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងអំឡុងពេល
សវនាការបឋមស្តីពីសម្បទាចូលរួមក្នុង សវនាការ ពីឯកសារសម្ងាត់បំផុតទៅជាឯកសារសម្ងាត់
និងជូនដំណឹងដល់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់អំពីឯកសារទាំងនោះ

៩. អាស្រ័យហេតុនេះ គេគួរតែបកស្រាយថាសេចក្ដីប្រកាសរបស់ចៅក្រមក្នុងអំឡុងពេលសវនាការនៅថ្ងៃទី ២៩ និង ៣០ ខែ សីហា ជាការទទួលស្គាល់ថាឯកសារទាំងនេះ បានក្លាយជា "ឯកសារសាធារណៈ"រួចទៅហើយ។ ទោះបីជាយ៉ាងណា នៅពេលនេះឯកសារទាំងនេះ នៅតែជាចាត់ថ្នាក់ជាឯកសារសម្ងាត់បំផុតនៅក្នុងសំណុំរឿងនៅឡើយ។

១០. វាហាក់ដូចជាមិនសមហេតុផល ដែលនៅតែចាត់ថ្នាក់ឯកសារទាំងនោះជាឯកសារសម្ងាត់បំផុតដដែល នៅពេលខ្លឹមសារនៃឯកសារទាំងនោះ និងឯកសារទាំងស្រុងមួយចំនួនត្រូវបានអានក្នុងពេលសវនាការសាធារណៈរួចហើយ។ អាស្រ័យហេតុនេះ មិនមានយុត្តិកម្មសមស្របក្នុងការរក្សាចំណាត់ថ្នាក់ឯកសារទាំងនេះជាឯកសារសម្ងាត់បំផុតឡើយ ដោយហេតុថាឯកសារទាំងនោះលែងជាឯកសារសម្ងាត់បំផុតហើយ។

**សំណើ**

យោងតាមសំអាងហេតុខាងលើ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើអង្គជំនុំជម្រះសាលាដំបូង៖

(១) ចាត់ថ្នាក់ឡើងវិញ និងចាត់ថ្នាក់ជាឯកសារសម្ងាត់នៅក្នុងសំណុំរឿងនូវឯកសារទាំងឡាយទាក់ទងនឹងសម្បទារបស់ជនជាប់ចោទ ដែលចុះបញ្ជីខាងក្រោមនេះ ៖ A100/I, A134/I, A195/I/1, A195/I/2, A38/I, B12, B14/1, B15/1, B16, B17, B18, B19, B2, B25/1, B27/1, B29/1, B3, B39/1, B41/1, B45, B46/1, B48/1, B5, B6, D24/II, D24/IV, D24/IX, D24/VII, D76/III, D76/IV, E10/1, E10/10, E10/11, E10/12, E10/13, E10/14, E10/15, E10/2, E10/3, E10/31, E10/32, E10/4, E10/5, E10/6, E10/7, E10/8, E10/9, E11, E11/1, E11/10, E11/11, E11/12, E11/13, E11/14, E11/15, E11/2, E11/3, E11/4, E11/5, E11/6, E11/7, E11/8, E11/9, E12, E12/1, E12/10, E12/11, E12/12, E12/13, E12/14, E12/15, E12/2, E12/3, E12/31, E12/32, E12/4, E12/5, E12/6, E12/7, E12/8, E12/9, E17.1, E17/1/2.3, E17/1/2.4, E17/1/2.5, E17/1/2.6, E62/2, E62/2.1, E62/3/1/1, E62/3/12, E62/3/12.1, E62/3/12.2, E62/3/13, E62/3/13, E62/3/13/Corr-1, E62/3/3.1, E62/3/4.1, E62/3/4.2, E62/3/4.3, E62/3/4/1, E62/3/4/1.1, E62/3/4/1.1.2, E62/3/4/2, E62/3/4/2.1, E62/3/4/2.1.1, E62/3/5/Corr-1, E62/3/6.1, E62/3/6.2, E62/3/6.3l, E62/3/6.4, E62/3/6.5, E62/3/6/1, E62/3/6/2, E62/3/6/2.1, E62/3/6/2.1.1,

E62/3/6/3, E62/3/6/3.1, E62/3/6/4, E62/3/6/4.1, E62/3/6/4.2, E62/3/6/4.2/Corr-1, E62/3/6/4.3, E62/3/6/4.4, E62/3/6/4/Corr-1, E62/3/6/5, E62/3/6/5.1, E62/3/6/5/Corr-1។

(២) បង្គាប់ឲ្យក្រឡាបញ្ជីជូនដំណឹងមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីឯកសារពាក់ព័ន្ធ (សូមមើលបញ្ជីឯកសារដែលភ្ជាប់ជាមួយ)។

សូមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើទាំងនេះដោយអនុគ្រោះ។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ១២ កញ្ញា ២០១១ | **លោក ពេជ អង្គ**<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | |
| | **លោកស្រី Elisabeth SIMONNEAU FORT**<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | |